# ការហ្វឹកហាត់

# នៃសាសនាជាអ្វី?

ក្នុងចំណោម ការហ្វឹកហាត់ពេលវេលា នៅក្នុងព្រះ ដែលមានប្រសិទ្ធភាព ហើយ សំខាន់ជាងគេនោះគឺ ពេលវេលាដែល យើងថ្វាយទៅព្រះ ជាពេលវេលាស្ងៀម ស្ងាត់ ដោយសញ្ជឹងគិតព្រះបន្ទូលព្រះ ដែលយើងហៅថា ពេលស្ងៀមស្ងាត់

( Quiet Time )

ជំនឿរបស់យើងគឺប្រៀបដូចជាទឹកនោចទឹកនាចអញ្ជើង។ ហើយដែលចិត្តយើងកំពុងតែមានលំហូបែបនេះ យើងអាចហៅបានថា **ជាទំនោចិត្ត**

- នៅក្នុងទំនោចិត្តរបស់មនុស្សយើង គឺមាន២យ៉ាង

ព្រះជាម្ចាស់ ← **<u>ចិត្ត</u>** → លោកិយ

(ខាងឯ ព្រលឹង) ( ខាងឯសាច់ឈាម)

* តើធ្វើដូចម្តេចទើបយើងអាចដឹងថាទំនោចិត្តយើងទៅខាងណា?

* ហើយតើធ្វើដូចម្តេចដើម្បីឲ្យទំនោចចិត្តរបស់យើងទៅកាន់ព្រះ?

# សូមអានព្រះគម្ពីរ ២ធីម៉ូថេ ៣: ១~៥

១ ចូរឲ្យដឹងថា នៅជាន់ក្រោយបង្អស់ នឹងមានគ្រា
លំបាកណាស់ ២ ដ្បិតនៅគ្រានោះ មនុស្សនឹង
ស្រឡាញ់តែខ្លួនឯង ទាំងស្រឡាញ់ប្រាក់ អួតអាង
គយរ មានឫកខ្ពស់ ប្រមាថមើលងាយ មិនស្តាប់
បង្គាប់ឪពុកម្តាយ រមីលគុណ មានចិត្តមិនបរិសុទ្ធ

៣ មិនស្រឡាញ់តាមធម្មតាមនុស្ស គ្មានសេចក្តីអធ្យាគ
និយាយបង្កាច់គេ មិនចេះទប់ចិត្ត មានចិត្តសាហាវ មិន
ចូលចិត្តនឹងការល្អ ៤ ក្បត់គេ ឥតបើគិត មានចិត្តធំ
ហើយចូលចិត្តនឹងល្បែងលេងជាជាងព្រះ ៥ គេមានឫក
ពាជាអ្នកគោរពប្រតិបត្តិដល់ព្រះ ប៉ុន្តែមិនព្រមទទួល
ស្គាល់ព្រះចេស្តា ដែលមកដោយការគោរពប្រតិបត្តិ
នោះទេ ចូរបែរពីពួកមនុស្សយ៉ាងនោះចេញ

# កាឡាទី ៥: ១៩~២១

១៩ រីឯកិច្ចការខាងសាច់ឈាម
នោះប្រាកដច្បាស់ហើយ គឺជាសេចក្តី កំផិត សហាយស្មន់
ស្មោកគ្រោក អាសអាភាស ២០ ថ្វាយបង្គំរូបព្រះ មន្តអាគម
សំអប់គ្នា ឈ្លោះប្រកែក ឈ្នានីស កំហឹង ទាស់ទែងគ្នា ឬាក់
បែក បក្សពួក ២១ ច្រណែន កាប់សំឡាប់ ប្រមឹក ស៊ីផឹកផ្តិល
និងការអ្វីទៀត ដែលស្រដៀងនឹងសេចក្តីទាំងនេះផង ហើយខ្ញុំ
ប្រាប់អ្នករាល់គ្នាទុកជាមុន ដូចជាបានប្រាប់រួចមកហើយថា
អស់អ្នកដែលប្រព្រឹត្តដូច្នេះ នោះមិនបានគ្រងនគរព្រះ ទុកជា
មរដកឡើយ

- ដូចច្នេះតើការអ្វីខ្លះដែលយើងអាចក្លាយទៅជាអ្នកដែលមានទំនោទៅខាងឯព្រះបាន ?

តើយើងត្រូវមានអ្វីខ្លះដើម្បីឲ្យដូចជាអង្គទ្រង់នៃយើង ?

# កាឡាទី ៥: ២២~២៣

២២ តែឯផលផ្លែនៃព្រះវិញ្ញាណវិញ នោះគឺ
សេចក្ដីស្រឡាញ់ អំណរអរ មេត្រីភាព
អត់ធ្មត់ សុភាព សប្បុរស ស្មោះត្រង់
២៣ ស្លូតបូត ហើយដឹងខ្នាត គ្មានក្រឹត្យវិន័យ
ណាទាស់នឹងសេចក្ដីយ៉ាងនោះទេ

សូមបែងចែកជាក្រុម ហើយចែក

រំលែកគំនិតនិងការសារភាពរបស់ខ្លួន